# មហាព្រះវេស្សន្តរជាតក (សង្ខេប)

*កណ្ឌទសពរ (ទី១)*

ព្រះបរមសាស្ត្រាចារ្យ កាលគង់ក្នុងវត្តនិគ្រោធារាម នគរកបិលព័ស្តុ ទ្រង់ប្រារព្ធនូវភ្លៀងបោក្ខរព័ស ទ្រង់សម្ដែងព្រះធម៌ទេសនានេះថា **ផុស្សតិ វរវណ្ណាភេ** ដូច្នេះជាដើម។ សេចក្ដីពិតថា កាលដែលព្រះបរមសាស្ត្រាចារ្យទើបបានត្រាស់ទ្រង់គង់ក្នុងនគររាជគ្រឹះអស់ហេមន្តរដូវ ទ្រង់មានព្រះភិក្ខុសង្ឃអង្គអរហន្តចំនួន២០ពាន់អង្គជាបរិវារ ទ្រង់យាត្រានិវត្តមកកាន់នគរកបិលព័ស្តុវិញ មានព្រះឧទាយីដែលព្រះបាទស្រីសុទ្ធោទន៍ទៅនិមន្តនោះជាមគ្គុទ្ទេសក៍។ គ្រានោះពួកស្ដេចសក្យរាជ ព្រមព្រៀងគ្នាកំណត់យកសួនច្បារជារមណីដ្ឋានរបស់ដែនសក្កៈឈ្មោះ **និគ្រោធារាម** ថ្វាយជាអារាម ផ្ដាច់មកចំពោះព្រះពុទ្ធជាម្ចាស់។ ព្រះរាជាទាំងនោះកាលយាងទៅធ្វើបដិសណ្ឋារៈ ចំពោះព្រះបរមគ្រូ ទ្រង់តែងតែរុញពួកយុវក្សត្រដែលក្មេងៗ ជាងព្រះពុទ្ធឲ្យចូលទៅគង់ខាងមុខៗ ឯពួកព្រឹទ្ធរាជ (ស្ដេចចាស់) ក្រាញនៅតែខាងក្រោយៗ ដោយកិរិយាពុំព្រមថ្វាយព្រះបង្គំព្រះបរមសាស្ដា។

ព្រះភគវន្តាចារ្យ ទ្រង់ថ្វាយអធ្យាស្រ័យនៃពួកព្រះញាតិទាំងនោះ ទើបទ្រង់ចូលទៅកាន់ចតុត្ថជ្ឈាន ហោះទៅកាន់អាកាសវេហាសន៍ មហារាជជាពុទ្ធបិតាទ្រង់ទស្សនានូវសេចក្ដីអស្ចារ្យទ្រង់ផ្គងព្រះអញ្ជលីលើព្រហសិរសី។ កាលព្រះចក្រីថ្វាយបង្គំហើយ ឥតមានស្ដេចណាមួយឡើយដែលមិនថ្វាយបង្គំសោះ។ កាលស្ដេចទាំងអស់នោះថ្វាយបង្គំហើយ ព្រះពុទ្ធជាម្ចាស់ទ្រង់ចុះអំពីអាកាសមកគង់លើព្រះបវរពុទ្ធអាសន៍ កណ្ដាលញាតិសមាគម។ លំដាប់នោះ មហាមេឃក៏បង្អុរមកនូវភ្លៀងបោក្ខព័ស់ដ៏អស្ចារ្យ។ គឺថាជនណាចង់ទទឹក ទើបទទឹក ជនណាពុំចង់ទទឹកក៏ឥតទទឹកឡើយ។ ប្រជាជនទាំងអស់បានឃើញភ្លៀងនោះប្រឹងតែស្ញើចប្រឹងតែសរសើរថា: ឱ! អស្ចារ្យណាស់តើហ្ន៎! ឱ! ចំឡែកប្លែកត្រកាលណាស់តើហ្ន៎! ឱ! អានុភាពនៃព្រះពុទ្ធអើយធំអ្វីមាល្បាលម៉្លេះហ្ន៎!។ ព្រះបរមសាស្ដាទ្រង់មានព្រះពុទ្ធដីកាថា: មិនមែនតែឥឡូវនេះទេ! ពីបុព្វេ គឺកាលតថាគតជាព្រះពោធិសត្វ ក៏មហាមេឃបង្អុរភ្លៀង

បោក្ខព័ស់មានសភាពយ៉ាងនេះ ក្នុងញាតិសមាគមដែរ។ កាលភិក្ខុទាំងឡាយអារាធនាសុំទ្រង់សម្តែង ក៏ព្រះអង្គទ្រង់ថ្លែងនូវបុព្វប្រវត្តិថា:

***អតីត ភិក្ខវេ*** ម្នាលភិក្ខុទាំងឡាយ! កាលកន្លងទៅហើយ ព្រះរាជាព្រះនាម ***សិវិមហារាជ*** សោយរាជក្នុងនគរជេតុត្តរ ***សិវិរដ្ឋ*** ទ្រង់មានព្រះរាជបុត្រព្រះនាម ***សញ្ជ័យ***។ ទ្រង់នាំព្រះរាជកញ្ញាព្រះនាម ***ផុស្សតី*** ជាព្រះរាជបុត្រីនៃព្រះបាទ ***មទ្ទរាជ*** អំពីដែនមទ្ទរដ្ឋមកហើយ ទ្រង់ផ្ទេររាជសម្បត្តិរៀបអភិសេកព្រះសញ្ជ័យរាជកុមារ និងព្រះនាងផុស្សតិជាអគ្គមហេសីក្នុងព្រះសិវីរាជសម្បត្តិជាព្រះមហាក្សត្រតពីព្រះអង្គមក។

បុព្វយោគនៃនាងផុស្សតីនោះដូច្នេះគឺ ក្នុងកាលជាទីបំផុតនៃកប្ប ៩១ (រាប់ច្រាស់ទៅក្រោយ) ព្រះនាងផុស្សតីនេះជាព្រះរាជបុត្រីនៃព្រះបាទ ***ពន្ធុរាជ*** នគរពន្ធុមតី បានថ្វាយលម្អិតខ្លឹមច័ន្ទន៍ចំពោះព្រះពុទ្ធ ***វិបស្សី*** លុះនាងអន្ទោលទៅក្នុងទេវលោក និងមនុស្សលោករមែងមានខ្លឹមច័ន្ទន៍ផ្សាយចេញអំពីព្រះអង្គកាយជាប្រក្រតី រហូតដល់ជាតិដែលនាងជាព្រះអគ្គមហេសីនៃព្រះឥន្ទ្រាធិរាជ ក្នុងភទ្ទកប្បនេះក៏នៅតែមានខ្លឹមច័ន្ទន៍ផ្សាយចេញអំពីព្រះកាយដូច្នោះដែរ ទើបនាងបានព្រះនាមថា ***ផុស្សតី***។ កាលដែលព្រះនាងដល់កំណត់ព្រះជន្មាយុព្រះឥន្ទ្រទ្រង់ជ្រាបថា ព្រះនាងនឹងច្យុតក៏ទ្រង់នាំព្រះនាងទៅកាន់នន្ទវ័នឧទ្យានផ្តេកព្រះនាងលើអលង្កតសិរិសយនា ហើយទ្រង់ត្រាស់ព្រះរាជឱង្ការថា:

***ផុស្សតិ វរវណ្ណាភេ វរស្សុ ទសធា វរេ***
***បឋព្យា ចារុបុព្វង្គី យំ តុយ្ហំ មនសោ បិយំ***

ម្នាលនាងផុស្សតីមានរស្មីនៃសម្បុរដ៏ប្រសើរ មានអវយវៈដ៏ល្អលើសគេលើផែនដី ចូរនាងទទួលពរ១០ប្រការ ដែលជាពរពេញចិត្តរបស់នាង (នាងចង់សម្រេចចិត្តយ៉ាងណា ចូរប្រាថ្នាយ៉ាងនោះចុះ ខ្ញុំនឹងប្រសិទ្ធីឲ្យនាង)។

ព្រះនាងផុស្សតី ពុំជ្រាបថានឹងច្យុតក៏ឆ្ងល់នឹងព្រះរាជឱង្ការដែលឲ្យព្រះនាងសុំពរនោះ ទើបក្រាបបង្គំទូលសួរថា: បពិត្រទេវរាជ ខ្ញុំម្ចាស់មានកំហុសខុសត្តង់ដូចម្តេច បានជាព្រះអង្គមានព្រះឱង្ការ ហាក់ដូចជានឹងបណ្តេញខ្ញុំម្ចាស់ឲ្យឃ្លាតចាករមណីដ្ឋានយ៉ាងនេះ។

អត្ថបទដោយ៖ មាស សុភាព

*ព្រះឥន្ទ្រប្រាប់ថា: នាងឥតកំហុសអ្វីទេ នាងមិនមែនជាទីសម្អប់នៃខ្ញុំទេ តែថានាងអស់បុណ្យហើយ បានជាខ្ញុំនិយាយនឹងនាងយ៉ាងនេះ នាងមានសេចក្ដីស្ងាប់ជិតកៀកណាស់ហើយ។*

*នាងផុស្សតីសូមពរថា: បពិត្រទេវរាជជាឥសូរ កំពូលលើក្នុងពួកទេវតា បើព្រះអង្គទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់! ខ្ញុំម្ចាស់សូម!៖*

១ ឲ្យបានជាអគ្គមហេសី នៃព្រះបាទស្រីសញ្ជ័យ នានគរជេតុត្តរ។

២ ឲ្យបានភ្នែកល្អ មានកូមោកោង ទ្រទេសទ្រទួយដូចបង្គួយកៅទណ្ឌ។

៣ មានឈ្មោះថា **ផុស្សតី** ដដែល។

៤ ឲ្យមានកូនប្រុសមួយមានកិត្តិនាមល្បីល្បាញ។

៥ ពេលមានគត៌សូមឲ្យមានផ្ទៃពោះស្មើល្អដូចប្រក្រតី។

៦ កុំឲ្យមានដោះសណ្ដាយ។

៧ កុំឲ្យមានសក់ស្កូវ។

៨ ឲ្យមានសាច់សម្បុរស្បែកម៉ដ្ឋខៃដូចសាច់ពពិលមាស។

៩ ឲ្យមានអំណាច អាចដោះទុក្ខទោសរបស់មនុស្សសត្វទាំងឡាយ។

១០ ឲ្យមានបក្សី គឺហង្ស ក្រៀល ក្ងាន ក្ងោក បន្ទឺន្ទូវស័ព្ទល្វេងលើយជិតព្រះរាជមន្ទីរ។

*ព្រះឥន្ទ្រាធិរាជទ្រង់បានព្រះរាជទានព្រះពរទាំង១០ប្រការ ទ្រង់បានប្រិសទ្ធីឲ្យបានសម្រេចដូចមនោរថរបស់ព្រះនាង។*

**(ចប់កណ្ឌទសពរ ទី១ សូមរង់ចាំតាមដានកណ្ឌទី២ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព